# ការចិញ្ចឹមទា តាមបច្ចេកទេសបែបវិទ្យាសាស្ត្រធម្មជាតិ

## ១- ការជ្រើសរើសពូជ

- ជាទាជំនាន់ អ៊ី អ៊ិក្ស អិម ដែលបង្កើតឡើងដោយការភ្ញាស់ចេញពីពងទា អ៊ី អ៊ិក្ស អិម ។
- ជ្រើសរើសយកកូនទាដែលមានឆ្អឹងរឹងមាំ ។
- ដងខ្លួនមានរាងជាចតុកោណស្មើ ។
- ឆ្អឹងគុម្ពកន្ទុយរន្ធគូថត្រូវឃ្លាតឆ្ងាយពីគ្នាចំពោះទាមេ ចំណែកឯទាបាវិញត្រូវឆ្អឹងនៅជិតគ្នា ។

## ២- ការសង់ទ្រុងទា

- ការសង់ទ្រុងទាត្រូវធ្វើឡើងនៅតាមបណ្ដោយថ្ងៃ ។ បណ្ដោយទ្រុង ១០ម៉ែត្រ និងទទឹង ៤ ម៉ែត្រ ។ តំរូវចំនួន ២៥០ ទៅ ៥០០ក្បាល ។ ការធ្វើទ្រុងបែបនេះជាការចិញ្ចឹមតាមលក្ខណៈគ្រួសារ ។
- ជុំវិញទ្រុងដែលសង់គួរតែយកស្បៃនីឡុងព័ទ្ធជុំវិញ ឬយកសំណាញ់ដែកព័ទ្ធជុំវិញឬយកសំណាញ់ដែកព័ទ្ធជាការប្រសើរ ដើម្បីការពារសត្វផ្សេងៗមកយាយីជីវិតសត្វទា និងការចំលងមេរោគ ។
- ចំពោះដំបូលទ្រុង គួរតែប្រក់ស្លឹកធ្វើពីស្បូវ ជៀសវាងយកដែកមកប្រក់ ជាហេតុបណ្ដាលអោយឡើងកំដៅនៅពេលរដូវក្ដៅ ។
- កំពស់រោងទា ប្រមាណ ១.៥ម៉ែត្រ ទៅ ២ម៉ែត្រ ។
- នៅក្នុងទ្រុងទាត្រូវក្រាលអង្កាមរស់ ឬមិនបាច់ក៏បានដែរ បើក្រាលវាចំណេញការធ្វើជីអង្កាមរស់ដើម្បីយកទៅដាក់ស្រែ ។

## ៣- ការថែទាំកូនទា

- កូនទាដែលញាស់បាន ១សប្ដាហ៍ហើយ ត្រូវយកមេ អ៊ី អ៊ិក្ស អិម បញ្ច្រាកក្នុង ១ក្បាល ១សេសេ ។

- បើអាកាសធាតុប្រែប្រួលត្រជាក់ខ្លាំង យើងត្រូវយកក្អមមកចងព្យួរ ដុតធ្យូងដើម្បីរក្សាសីតុណ្ហភាព បើសិនជាស្ថិតនៅក្នុងរដូវប្រាំងវិញ លើផ្ទៃដែលកូនទារស់នៅមិនចាំបាច់ក្រាលអង្កាមទេ ។
- យកមេ អ៊ី អ៊ិក្យ អិម ១លីត្រ លាយជាមួយទឹកស្អាត ១០០០០លីត្រ អោយកូនទាផឹកជារៀងរាល់ថ្ងៃ (ទឹកស្អាត ១០លីត្រ លាយមេអ៊ី អ៊ិក្យ អិម ១សេសេ) ។ ទឹកដែលលាយនេះមិនអាចទុកលើសពី ២៤ម៉ោងទេ បើទាផឹកមិនអស់ត្រូវជះទៅលើកន្លែងដែលមានក្លិនស្អុយហើយយើងចាប់លាយសារជាថ្មីដោយអនុវត្តន៍តាមរបៀបនេះជារៀងរាល់ថ្ងៃ បើសិនជាមានជំងឺក៏ ងាយស្រួលនឹងព្យាបាលដែរ ។
- ឧស្សាហ៍ព្យាយាមសង្កេតមើលដំណើរសកម្មភាពទាទាំងឡាយនោះ បើទាណាមានការប្រែប្រួល ត្រូវចាប់មកបញ្ច្រកមេ អ៊ី អ៊ិក្យ អិម ចាប់ពី ១-៣សេសេ ចំពោះទា ១ក្បាល ហើយទុកមួយកន្លែងសិន ។ បើសិនជាសះស្បើយហើយទើបយើងបញ្ចូលក្នុងហ្វូងវិញ តែបើសិនជានៅមានបញ្ហាទៀតសូមទំនាក់ទំនងមកក្រុមហ៊ុនដើម្បីយកថ្នាំបសុសត្វទៅព្យាបាល ។
- យកម្សៅសំរិទ្ធ ១កញ្ចប់តូច លាយជាមួយចំណីមាន់ ៥គីឡូក្រាម ក្នុងមួយសប្តាហ៍ អោយមាន់ស៊ី ១ ឬ២ដង
- យកម្សៅសំរិទ្ធ ១កញ្ចប់តូច លាយជាមួយទឹកស្អាត ៥លីត្រ អោយមាន់ផឹកមួយសប្តាហ៍ ២ដង ។
- នៅជុំវិញបរិវេណ ដែលទាតែងតែរស់នៅ (ទ្រុង មាត់ស្រះទឹក ទឹកស្រះ) គួរតែបាញ់ អ៊ី អ៊ិក្យ អិមបំផ្លាញបាក់តេរីអាក្រក់ ក្នុង១សប្តាហ៍ ១ ទៅ ២ដង ទោះជាត្រូវកូនទា ទាធំក៏ មិនអីដែរ (១:២៥០) ។ ការធ្វើបែបនេះបរិស្ថានរស់នៅរបស់ទាល្អ ទាជៀសផុតពីជំងឺផ្សេងៗ បើចង់បានផលការចិញ្ចឹមត្រូវយកចិត្តទុកដាក់ ។

## ៤- ករណីទាមានជំងឺ

- ជំងឺទាទន់ជើង គេហៅថា ទាប៉ាប យើងប្រើមេ អ៊ី អ៊ិក្យ អិម បញ្ច្រក១ក្បាល ៣សេសេ ក្នុង១ថ្ងៃ៣ដង បើមិនបាត់ត្រូវបញ្ច្រកមេ អ៊ី អ៊ិក្យ អិម ១-២សេសេ លាយជាមួយបណ្តេញ ពណ៌ខៀវ របស់ក្រុមហ៊ុន ១-២សេសេ ។ បើនៅតែមិនជា សូមប្រើថ្នាំបសុសត្វរបស់ក្រុមហ៊ុនឈ្មោះអាមុក រឺទំនាក់ទំនងមកអ្នកជំនាញរបស់ក្រុមហ៊ុន ។

- ជំងឺក្រហមភ្នែក សូមប្រើម្សៅសំរិទ្ធលាយជាមួយមេ អ៊ី អ៊ិក្ស អ៊ិម នឹងចំណីអាហារអោយទាស៊ី។
- ក្នុងករណីមានជំងឺផ្សេងៗទៀតលើសពីនេះ ឬប្រើប្រាស់ទៅមិនមានប្រសិទ្ធិភាព សូមទំនាក់ទំនងមកក្រុមការងាររបស់យើងខ្ញុំ (០២៣ ៨៨ ២៥ ៥៥) ។

(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញ្ញូស៍)